១៦៥- លោក នាក់ វណ្ណៈ គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនតាកែវ

១៦៦- លោកស្រី សុត បូទុំសុវណ្ណ គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត

១៦៧- លោក សុន សុក្រិត្យ គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត

១៦៨- លោកស្រី គង់ កក្កដា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត

១៦៩- លោកស្រី ធន យ៉ា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត

១៧០- លោក ចាន់ ពិស្ណុរ គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត

១៧១- លោក ផាន់ សុភាព គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនស្វាយរៀង

១៧២- លោក ចាន់ រិទ្ធី គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប

១៧៣- លោកស្រី ពេជ្រ ល្អាច គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប

១៧៤- លោកស្រី អ៊ាវ ចាន់ឌី គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប

១៧៥- លោក ផៃ មិថុនា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង

១៧៦- លោក រឿត ច័ន្ទតារា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង

១៧៧- លោក ដាំ កិត្យា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង

១៧៨- លោក ហេង ឧស្សាហ៍ គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង

១៧៩- លោកស្រី យ៉ុន សំនាង គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង

១៨០- លោកស្រី ផា កញ្ញា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង

១៨១- លោក ឡាប វណ្ណឌី គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសមិត្តភាព កម្ពុជា-ចិន ខេត្តព្រះសីហនុ

១៨២- លោក ម៉ន ចាន់ណា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសមិត្តភាព កម្ពុជា-ចិន ខេត្តព្រះសីហនុ

១៨៣- លោក ណយ កក្កដា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តពោធិ៍សាត់

១៨៤- លោក ស៊ូ ស៊ុន គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ធំ

១៨៥- លោក វ៉ាន់ អៀង គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ធំ

១៨៦- លោក ចាប វណ្ណដែត គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ធំ

១៨៧- លោកស្រី កែវ វណ្ណា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសតេជោសែន

១៨៨- លោកស្រី ម៉ារ ម្លិះគន្ធ គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសតេជោសែន

១៨៩- លោកស្រី លី ដួននិមល គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសតេជោសែន

១៩០- លោក ង៉ុយ វ៉ុន គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសតេជោសែន

១៩១- លោកស្រី លន់ ច័ន្ទសិរី គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសតេជោសែន

១៩២- លោក ដៀស តារា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសតេជោសែន

១៩៣- លោក ឆឹង ឆៃយ៉ា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសតេជោសែន

១៩៤- លោក ខាត់ ញ៉ុត គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ស្ពឺ

១៩៥- លោក វៀម សុភា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ស្ពឺ

១៩៦- លោក សុខ សុផានិត គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកោះកុង

១៩៧- លោក ឈឹម ប្រុស គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រៃវែង

១៩៨- លោក គង់ គឿន គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រៃវែង

១៩៩- លោក ហ៊ី ប៊ុនណា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ឆ្នាំង

២០០- លោក ផុន មករា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ឆ្នាំង

២០១- លោក សាន សុជារិទ្ធ គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះវិហារ

២០២- លោក ជន សុខពុទ្ធា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះវិហារ

២០៣- លោកស្រី ហួ ធារី គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគ តេជោសែនឦសាន

២០៤- លោក សែម ដេ្ឋា គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគ តេជោសែនឦសាន

| | | | |
|---|---|---|---|
| ២០៥- | លោក | សៀង ភារី | គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនព្រៃសាន |
| ២០៦- | លោកស្រី | លាង សុភាព | គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនព្រៃសាន |
| ២០៧- | លោកស្រី | ប៊ុន អូន | គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនព្រៃសាន |
| ២០៨- | លោក | រឹង សារ៉ែន | គ្រូបង្រៀនកម្រិតមូលដ្ឋាន នៃវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ |
| ២០៩- | លោក | វេង សេងហុង | គ្រូបង្រៀនកម្រិតមូលដ្ឋាន នៃវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម |
| ២១០- | លោក | ណុន វណ្ណនាត | គ្រូបង្រៀនកម្រិតមូលដ្ឋាន នៃវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម |
| ២១១- | លោកស្រី | គយ ស្រីលក្ខ័ណ៍ | គ្រូបង្រៀនកម្រិតមូលដ្ឋាន នៃវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម |
| ២១២- | លោក | ផេង វាយោ | គ្រូបង្រៀនកម្រិតមូលដ្ឋាន នៃវិទ្យាស្ថានបច្ចេកទេស ហ៊ីុ វ៉េ សេ |
| ២១៣- | លោក | ប្រេស ច័ន្ទនា | គ្រូបង្រៀនកម្រិតមូលដ្ឋាន នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនតាកែវ |
| ២១៤- | លោក | ម៉ៅ តុលា | គ្រូបង្រៀនកម្រិតមូលដ្ឋាន នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត |
| ២១៥- | លោក | ឈឿម ចាន់ឌីណា | គ្រូបង្រៀនកម្រិតមូលដ្ឋាន នៃវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ |
| ២១៦- | លោក | ពេជ្រ មន្នី | គ្រូបង្រៀនកម្រិតមូលដ្ឋាន នៃវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង |
| ២១៧- | លោក | សឹង សិរីវឌ្ឍន៍ | គ្រូបង្រៀនកម្រិតមូលដ្ឋាន នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តពោធិ៍សាត់ |
| ២១៨- | លោក | ឌុល ចាន់និកា | គ្រូបង្រៀនកម្រិតមូលដ្ឋាន វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនព្រៃសាន |
| ២១៩- | លោក | ទឹម សុតចន | គ្រូបង្រៀនកម្រិតមូលដ្ឋាន នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តត្បូងឃ្មុំ |
| ២២០- | លោក | អ៊ី សំអាន | គ្រូបង្រៀនកម្រិតឧត្តម នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តប៉ៃលិន |
| ២២១- | លោក | ចៃ មីនី | គ្រូបង្រៀនកម្រិតឧត្តម នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តប៉ៃលិន |
| ២២២- | លោកស្រី | គឹម រស្មី | គ្រូបង្រៀនកម្រិតឧត្តម នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តត្បូងឃ្មុំ |
| ២២៣- | លោក | នាង វណ្ណា | មន្ត្រី នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ |
| ២២៤- | លោក | អ៊ិន ដារ៉ាម | មន្ត្រី នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពត |
| ២២៥- | លោកស្រី | យ៉ង់ ចន្ថា | មន្ត្រី នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកែប |
| ២២៦- | លោក | លន ចាន់ធឿន | មន្ត្រី នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកែប |
| ២២៧- | លោកស្រី | ជឹម ចន្ទិតា | មន្ត្រី នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ស្ពឺ |

២២៨- លោក ហ៊ឹម វាសនា មន្ត្រី នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង

២២៩- លោកស្រី ស៊ុន សុគន្ធារ៉ា មន្ត្រី នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប។

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១១៩ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**មាត្រា១.-**

ត្រូវបានបំពាក់មេដាយ **មុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៤៥រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១- | លោក | ហ៊ាន សាវិរិសនា | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ២- | លោក | ព្រាប រ៉ាវន់ | នាយករងវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនស្វាយរៀង |
| ៣- | លោក | ជួប វណ្ណៈ | ប្រធានការិយាល័យ នៃនាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម |

៤- លោកស្រី កែវ សម្បត្តិ ប្រធានការិយាល័យ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

ខ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា**

១- ឯកឧត្តម នួន ចំណូល អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គណៈវិស្វករកម្ពុជា
២- លោក ឡុង ប៉ូឡែត អគ្គាធិការរង នៃអគ្គាធិការដ្ឋាន
៣- លោក ជា ស៊ាងហុង អនុប្រធាននាយកដ្ឋានវិវាទការងារ
៤- លោក ហ៊ុំ ចាន់ធី អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
៥- លោក ខាត់ ប៊ុនថន អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
៦- លោក លីម ស្រ៊ុនហ៊ាប អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
៧- លោកស្រី សៅ ច័ន្ទដាវី អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
៨- លោក អ៊ុក វ៉ាវុធ អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម
៩- លោក គង់ សំណាង នាយករងវិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍
១០- លោក ស្វាយ ចំឫទ្ធិ នាយករងវិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង
១១- លោក សុខ សុផាណារិទ្ធ ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
១២- លោកស្រី ហ៊ូ សុគន្ធាវី ប្រធានការិយាល័យ នៃនាយកដ្ឋានបណ្តុះបណ្តាល
១៣- លោក វ៉ន សុភ័ក្ត្រ អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល
១៤- លោក អ៊ឹម ចំរើន អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប
១៥- លោកស្រី ប៊ុន ច្រិប អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសៀមរាប
១៦- លោក នុត សោភ័ណ មន្ត្រី នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ។

គ-មេដាយ **មុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ**

១- លោក ឡាំ ប្រុស អគ្គនាយករង នៃអគ្គនាយកដ្ឋានការងារ
២- លោកស្រី ហាម សូលក្ខណ៍ ប្រធានផ្នែក នៃអគ្គលេខាធិការដ្ឋាន គណៈវិស្វករកម្ពុជា
៣- លោក វង្ស សុវណ្ណតារា ប្រធានផ្នែក នៃអគ្គលេខាធិការដ្ឋាន គណៈវិស្វករកម្ពុជា
៤- លោកស្រី សុក សុផារី អនុប្រធាននាយកដ្ឋាន បេឡាជាតិសន្តិសុខសង្គម
៥- លោក ម៉ៅ គីមលី អនុប្រធាននាយកដ្ឋាន បេឡាជាតិសន្តិសុខសង្គម
៦- លោក ពៅ ពន្លឺង អនុប្រធាននាយកដ្ឋាន បេឡាជាតិសន្តិសុខសង្គម
៧- លោកស្រី ផាន ម៉ារីណា អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
៨- លោក គឹម លីហួរ អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
៩- លោក ហ៊ា ស៊ុនលាភ នាយករងវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប
១០- លោក ចក់ សុខណា ប្រធានការិយាល័យ នៃនាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម
១១- លោក បូរ ជ័យសម្បត្តិ ប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក

| | | | |
|---|---|---|---|
| ១២- | លោក | តូច លីសុខ | ប្រធានដេប៉ាតឺម៉ង់វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស |
| ១៣- | លោក | ហ៊ិន ចាន់ណា | ប្រធានផ្នែក នៃវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ |
| ១៤- | លោកស្រី | ទូច វួចលាង | អនុប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ១៥- | លោក | ម៉ៅ សុថា | អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីភ្នំពេញ |
| ១៦- | លោក | ជុំ សុផល | អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល |
| ១៧- | លោក | មុំ សុត | អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកែប |
| ១៨- | លោក | ពៅ សានិត | អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបាត់ដំបង |
| ១៩- | លោក | អឿ សារេត | អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម |
| ២០- | លោកស្រី | យឿង អាយស្រ៊ុន | ប្រធានការិយាល័យ នៃវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនតាកែវ |
| ២១- | លោក | ស៊ីម វណ្ណរតនៈ | ប្រធានការិយាល័យ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល |
| ២២- | លោកស្រី | ផល ដាលីស | ប្រធានការិយាល័យ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តតាកែវ |
| ២៣- | លោក | សន ខេមរា | ប្រធានការិយាល័យ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ |
| ២៤- | លោក | មួង វ៉ាន់ | អនុប្រធានការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល និងបុគ្គលិក |
| ២៥- | លោក | ម៉ែន សុផាន | អនុប្រធានការិយាល័យ នៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២ កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១២០ អនក្រ.តត

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ .-**

ត្រូវបានបំពាក់មេដាយ **មាសការងារ** តាមលំដាប់ថ្នាក់ ជូននាយទាហាន នាយទាហានរង និងពលទាហាន នៃអគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច ចំនួន ៦២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិកន្លងមក ដូចមានរាយនាមខាងក្រោមៈ

ក-មេដាយ **មាសការងារ**

| | |
|---|---|
| ១- ឧត្តមសេនីយ៍ត្រី វ៉ាន់ សារិទ្ធ | អត្តលេខ២០០៣៦០១ នាយការិយាល័យភស្តុភារ ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច |
| ២- វរសេនីយ៍ទោ ឡេង យុទ្ធី | អត្តលេខ២៣៦៥១៨ នាយការិយាល័យទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស |

៣- វរសេនីយ៍ទោ ពិន អន អត្តលេខ២២៣៩៩៧ នាយរងការិយាល័យសន្តិសុខ នាយកដ្ឋានរដ្ឋបាល

៤- វរសេនីយ៍ត្រី ស៊ុន លុច អត្តលេខ១៦៣៥៥៦ នាយរងការិយាល័យបុគ្គលិក អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច។

ខ-មេដាយ **ប្រាក់ការងារ**

១- វរសេនីយ៍ទោ អេង ហ៊ុយឡេង អត្តលេខ១៦៥៦៩៩ នាយករងនាយកដ្ឋានសរុប-វិភាគព័ត៌មាន

២- វរសេនីយ៍ទោ ហេក លីជីនតា អត្តលេខ២៣០១៥៣ នាយរងការិយាល័យសរុបព័ត៌មាន នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស

៣- វរសេនីយ៍ទោ ហាង រិទ្ធី អត្តលេខ១៦៤៤០៦ នាយរងការិយាល័យព័ត៌មានវិទ្យា អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

៤- វរសេនីយ៍ទោ នុត ពិសី អត្តលេខ០៥៨៦៦៩ នាយរងការិយាល័យហិរញ្ញវត្ថុ នាយកដ្ឋានរដ្ឋបាល

៥- វរសេនីយ៍ត្រី អ៊ាង ផល្លា អត្តលេខ១៦៣៧៧៧ នាយរងការិយាល័យទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស

៦- វរសេនីយ៍ត្រី ជិន ស្រីនួន អត្តលេខ១៦៣៧៧៥ នាយផ្នែកគ្រប់គ្រងទ្រព្យសម្បត្តិរួម នាយកដ្ឋានរដ្ឋបាល

៧- វរសេនីយ៍ត្រី សន វណ្ណៈ អត្តលេខ០៦៦៦៨៥ ជំនួយការការិយាល័យសរុប នាយកដ្ឋានសរុប-វិភាគព័ត៌មាន

៨- វរសេនីយ៍ត្រី ជួប សុភត្រា អត្តលេខ០៦៧៦១៣ នាយផ្នែករដ្ឋបាល នាយកដ្ឋានប្រតិបត្តិការក្នុងប្រទេស

៩- វរសេនីយ៍ត្រី តឹក ស៊ាងលីម អត្តលេខ១៦៣៧៧១ នាយរងការិយាល័យភស្តុភារ-ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

១០- វរសេនីយ៍ត្រី ម៉ាន់ ចន្ថារី អត្តលេខ២២៦១៩៥ ជំនួយការការិយាល័យភស្តុភារ-ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

១១- អនុសេនីយ៍ឯក សួន ច័ន្ទភក្តី អត្តលេខ១៦៤៨៧២ ជំនួយការការិយាល័យបុគ្គលិក អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

១២- អនុសេនីយ៍ឯក មាស សុខគឹម អត្តលេខ១៦៦០៤១ ជំនួយការការិយាល័យបុគ្គលិក អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

១៣- អនុសេនីយ៍ឯក ង៉ៅ ភក្តី អត្តលេខ១៦៤៨១១ ជំនួយការការិយាល័យភស្តុភារ-ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

១៤- អនុសេនីយ៍ឯក នង តុលា អត្តលេខ១៩១៧០៨ ជំនួយការការិយាល័យភស្តុភារ-ហិរញ្ញវត្ថុ អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

១៥- អនុសេនីយ៍ឯក ជា ពៅរិត្យា អត្តលេខ២៣៩២៤០ នាយផ្នែករដ្ឋបាល នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស

១៦- អនុសេនីយ៍ឯក ព្រំ វិចិត្រ អត្តលេខ១៦៥៧១១ នាយរងការិយាល័យព័ត៌មានក្រៅប្រទេស នាយកដ្ឋានសរុប-វិភាគព័ត៌មាន

១៧- អនុសេនីយ៍ឯក អ៊ុក សុខរ៉ុម អត្តលេខ១៩៣៣១៥ នាយផ្នែករដ្ឋបាល នាយកដ្ឋានសរុប-វិភាគព័ត៌មាន

១៨- អនុសេនីយ៍ទោ ហេង ច័ន្ទរង្សី អត្តលេខ១៩៤៣៩២ នាយរងការិយាល័យព័ត៌មានក្នុងប្រទេស នាយកដ្ឋានសរុប-វិភាគព័ត៌មាន

១៩- អនុសេនីយ៍ទោ ហួន ព្រហស្បតិ៍ អត្តលេខ១៩៣២៨៥ ជំនួយការផ្នែករដ្ឋបាល នាយកដ្ឋានសរុប-វិភាគព័ត៌មាន

២០- អនុសេនីយ៍ទោ ជូ សេរីសុខា អត្តលេខ១៩២៩៣២ ជំនួយការសុខាភិបាល អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

២១- អនុសេនីយ៍ទោ ស៊ុន មករា អត្តលេខ២៤២៦៣៩ ជំនួយការសុខាភិបាល អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

២២- អនុសេនីយ៍ទោ ផន ផល្លី អត្តលេខ២៤៦០៨៤ ជំនួយការនាយកដ្ឋានរដ្ឋបាល។

គ-មេដាយ **សំរិទ្ធភារៈងារ**

១- វរសេនីយ៍ឯក រស់ សុជាតិ អត្តលេខ០១៤៩៥១ នាយក្រុមប្រតិបត្តិការខេត្តព្រះវិហារ សាខាទី៣ នាយកដ្ឋានប្រតិបត្តិការក្នុងប្រទេស

២- វរសេនីយ៍ទោ កូប ម៉ាត់ អត្តលេខ០១៤៧៧៩ ជំនួយការនាយកដ្ឋានប្រតិបត្តិការក្នុងប្រទេស

៣- វរសេនីយ៍ទោ ឌី ចាន់គីរុណា អត្តលេខ០១៤៧៩៤ ជំនួយការនាយកដ្ឋានប្រតិបត្តិការក្នុងប្រទេស

៤- វរសេនីយ៍ទោ ទី សារ៉ាវុធ អត្តលេខ០១៤៧៥៣ ជំនួយការនាយកដ្ឋានប្រតិបត្តិការក្នុងប្រទេស

៥- វរសេនីយ៍ទោ មិន ពៅ អត្តលេខ០២៤១៨៥ ជំនួយការនាយកដ្ឋានប្រតិបត្តិការក្នុងប្រទេស

៦- វរសេនីយ៍ទោ ពៅ សារ៉េត អត្តលេខ០២៤១៣៧ ជំនួយការនាយកដ្ឋានប្រតិបត្តិការក្នុងប្រទេស

៧- វរសេនីយ៍ទោ សឿន ស៊ុយ អត្តលេខ០២៤២០៧ ជំនួយការនាយកដ្ឋានប្រតិបត្តិការក្នុងប្រទេស

៨- វរសេនីយ៍ទោ សឿន តាំងសៀ អត្តលេខ០៥៦៨៧៦ នាយក្រុមប្រតិបត្តិការខេត្តកំពង់ឆ្នាំង សាខាទី១ នាយកដ្ឋានប្រតិបត្តិការក្នុងប្រទេស

៩- វរសេនីយ៍ទោ អ៊ិន សុភី អត្តលេខ០២៤០៥១ នាយក្រុមប្រតិបត្តិការខេត្តកំពង់ធំ សាខាទី៣ នាយកដ្ឋានប្រតិបត្តិការក្នុងប្រទេស

១០- វរសេនីយ៍ត្រី សៅ ភិន អត្តលេខ០២៤០៦៦ ជំនួយការការិយាល័យប្រតិបត្តិការចារកម្ម នាយកដ្ឋានប្រតិបត្តិការក្នុងប្រទេស

១១- វរសេនីយ៍ត្រី ថៃ ធឿន អត្តលេខ០២៤២៤៣ នាយរងក្រុមប្រតិបត្តិការខេត្តស្វាយរៀង សាខាទី២ នាយកដ្ឋានប្រតិបត្តិការក្នុងប្រទេស

១២- វរសេនីយ៍ត្រី ស៊ឹម សុផា អត្តលេខ០២៤១០១ ជំនួយការក្រុមប្រតិបត្តិការរាជធានីភ្នំពេញ សាខាទី១ នាយកដ្ឋានប្រតិបត្តិការក្នុងប្រទេស

១៣- វរសេនីយ៍ត្រី ឡេង ភិចឈៀ អត្តលេខ១៦៥៦២៦ ជំនួយការនាយកដ្ឋានរដ្ឋបាល

១៤- វរសេនីយ៍ត្រី ឃុត វិចិត្រ អត្តលេខ០៩៣៩៥៨ ជំនួយការអគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

១៥- វរសេនីយ៍ត្រី រស់ សេរីវឌ្ឍនា អត្តលេខ១៦៥៧០០ ជំនួយការការិយាល័យបុគ្គលិក អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

១៦- អនុសេនីយ៍ឯក គេន វណ្ណៈ អត្តលេខ១៦៥៧០៣ ជំនួយការការិយាល័យព័ត៌មានវិទ្យា អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

១៧- អនុសេនីយ៍ឯក ផន ពៅពិសិដ្ឋ អត្តលេខ១៦៥៧០៥ ជំនួយការការិយាល័យព័ត៌មានវិទ្យា អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

១៨- អនុសេនីយ៍ឯក ងួន លាងហន អត្តលេខ១៦៥៧០៦ ជំនួយការការិយាល័យព័ត៌មានវិទ្យា អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

១៩- អនុសេនីយ៍ទោ សោម សរសាន់ដេ អត្តលេខ១៦៩២៤៥ ជំនួយការការិយាល័យរដ្ឋបាល នាយកដ្ឋានរដ្ឋបាល

២០- អនុសេនីយ៍ទោ ពេជ ងិត អត្តលេខ១៦៩២២៣ ជំនួយការផ្នែករដ្ឋបាល នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស

២១- អនុសេនីយ៍ទោ សាយ គឹមសាន អត្តលេខ១៦៩២៨៦ ជំនួយការការិយាល័យសរុបព័ត៌មាន នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស

២២- អនុសេនីយ៍ទោ ផល រិទ្ធី អត្តលេខ២៤៨១០៥ ជំនួយការការិយាល័យប្រឆាំងភេរវកម្ម នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស

២៣- អនុសេនីយ៍ទោ ឈន បញ្ញារិទ្ធី អត្តលេខ១៩៣២០១ នាយរងការិយាល័យប្រមូលព័ត៌មាន នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស

២៤- អនុសេនីយ៍ទោ ថ្លៃ សំរិទ្ធ អត្តលេខ១៩៣២២២ ជំនួយការការិយាល័យទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស

២៥- អនុសេនីយ៍ទោ អិន តុលា អត្តលេខ១៦៤៧៥៣ ជំនួយការការិយាល័យទំនាក់ទំនងអន្តរជាតិ នាយកដ្ឋានប្រតិបត្តិការក្រៅប្រទេស

២៦- អនុសេនីយ៍ទោ ហៀត ធារូ អត្តលេខ១៦៩៦២៧ ជំនួយការអគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

២៧- អនុសេនីយ៍ទោ ភួន សុ៉ា អត្តលេខ១៦៩៦៩៥ ជំនួយការអគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

២៨- អនុសេនីយ៍ទោ គឹម ហេង អត្តលេខ១៦៩៨៨៣ ជំនួយការអគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

២៩- អនុសេនីយ៍ទោ នាត ស៊ីនឿន អត្តលេខ១៦៩៨២០ ជំនួយការអគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

៣០- អនុសេនីយ៍ទោ ឃឿត សុឃុន អត្តលេខ១៦៩៧៩៨ ជំនួយការអគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

៣១- អនុសេនីយ៍ទោ រិន សុវណ្ណា៉ អត្តលេខ០៦១២៦២ ជំនួយការការិយាល័យបុគ្គលិក អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច

| | | |
|---|---|---|
| ៣២- អនុសេនីយ៍ទោ | លឿង ច័ន្ទក្រឹស្នា | អត្តលេខ១៧០៧៦១ ជំនួយការការិយាល័យព័ត៌មានវិទ្យា អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច |
| ៣៣- អនុសេនីយ៍ត្រី | ស៊ាង ប្រសិទ្ធិ | អត្តលេខ១៧០៨០៩ ជំនួយការការិយាល័យព័ត៌មានវិទ្យា អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច |
| ៣៤- អនុសេនីយ៍ត្រី | លាង ពុទ្ធិ | អត្តលេខ១៧០៨១០ ជំនួយការការិយាល័យព័ត៌មានវិទ្យា អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច |
| ៣៥- អនុសេនីយ៍ត្រី | គឹម ដារ៉ា | អត្តលេខ១៧០៨១១ ជំនួយការការិយាល័យព័ត៌មានវិទ្យា អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច |
| ៣៦- ពលទោ | គិន ចាន់មករា | អត្តលេខ២៦៣៥០២ ជំនួយការការិយាល័យបុគ្គលិក អគ្គនាយកដ្ឋានស្រាវជ្រាវ-ចារកិច្ច។ |

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៨ សសរ

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួង សម្របសម្រួលលើការផ្ទេរសិទ្ធិកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ក្រោមជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ២០១៧ ស្តីពីវិធាន និង នីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីមុខងារ និង រចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅរដ្ឋបាលរាជធានី ខេត្ត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ :–**

ត្រូវបានបង្កើត **គណៈកម្មការអន្តរក្រសួង សម្របសម្រួលលើការផ្ទេរសិទ្ធិកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ក្រោមជាតិ** តទៅហៅថា "**គ.ផ.ទ.រ.**" ដើម្បីជានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព នៃការផ្ទេរសិទ្ធិកាន់កាប់ និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ក្រោមជាតិ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ២ :–**

**គ.ផ.ទ.រ.** មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| ១- រដ្ឋលេខាធិការ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក.ស.ហ.វ.) | ប្រធាន |
| ២- រដ្ឋលេខាធិការ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក.ស.ហ.វ.) | អនុប្រធានប្រចាំការ |
| ៣- រដ្ឋលេខាធិការ តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- រដ្ឋលេខាធិការ តំណាងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) | អនុប្រធាន |
| ៥- រដ្ឋលេខាធិការ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- រដ្ឋលេខាធិការ តំណាងក្រសួង ស្ថាប័ន ពាក់ព័ន្ធ | សមាជិក |
| ៧- អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃ ក.ស.ហ.វ. | សមាជិក |
| ៨- តំណាងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃ ក.ស.ហ.វ. | សមាជិក |
| ៩- តំណាងរដ្ឋបាលរាជធានី ខេត្ត ពាក់ព័ន្ធ | សមាជិក |
| ១០-ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ពាក់ព័ន្ធ | សមាជិក |
| ១១-ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ពាក់ព័ន្ធ | សមាជិក |
| ១២-អភិបាលនៃគណៈអភិបាលក្រុង ស្រុក ពាក់ព័ន្ធ | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ផ.ទ.រ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**ប្រការ៣ :–**

**គ.ផ.ទ.រ.**មានភារកិច្ចដូចខាងក្រោម៖



៥

- សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីផ្ទេរទ្រព្យសម្បត្តិរដ្ឋសម្រាប់គាំទ្រដល់ការផ្ទេរមុខងារទៅ រដ្ឋបាលថ្នាក់ក្រោមជាតិ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូល និងរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងឯកសារពាក់ព័ន្ធនឹងការផ្ទេរទ្រព្យសម្បត្តិរដ្ឋ
- ពិនិត្យ ផ្ទៀងផ្ទាត់ និងឯកភាពលើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវផ្ទេរពីអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋថ្នាក់ជាតិពាក់ព័ន្ធ ទៅអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋថ្នាក់ក្រោមជាតិពាក់ព័ន្ធ
- ធ្វើរបាយការណ៍ស្នើសុំការពិនិត្យ និងសម្រេចពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ឬ រាជរដ្ឋាភិបាល
- អនុវត្តការកិច្ចផ្សេងៗទៀត ដែលប្រធាន **គ.ផ.ទ.រ.** ប្រគល់ជូន។

**ប្រការ៤ :_**

អនុប្រធាន អនុប្រធានប្រចាំការ និងសមាជិកនៃ **គ.ផ.ទ.រ.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន **គ.ផ.ទ.រ.**។ ក្នុងករណីប្រធាន **គ.ផ.ទ.រ.** អវត្តមាន ឬ មានករណីចាំបាច់ ប្រធាន **គ.ផ.ទ.រ.** អាចផ្ទេរសិទ្ធិជូនអនុប្រធាន ឬ អនុប្រធានប្រចាំការ ដើម្បីដឹកនាំ សម្របសម្រួលកិច្ចប្រជុំជំនួស។

**ប្រការ៥ :_**

ប្រធាន **គ.ផ.ទ.រ.** មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្នើសុំអញ្ជើញមន្ត្រីបច្ចេកទេស នៃក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំ និងបំពេញការងារ ស្របតាមបទប្បញ្ញត្តិ ដែលដូចបានកំណត់ក្នុងសេចក្តីសម្រេចនេះ។

**ប្រការ៦ :_**

**គ.ផ.ទ.រ.** មានលេខាធិការដ្ឋានមួយ ជាសេនាធិការក្នុងការបំពេញកិច្ចការងាររបស់ខ្លួន។

លេខាធិការដ្ឋាន នៃ **គ.ផ.ទ.រ.** ដឹកនាំដោយ អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក.ស.ហ.វ. មានសមាសភាពពី អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃ ក.ស.ហ.វ., អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ នៃ ក.ស.ហ.វ. និង គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

សមាសភាពជាក់ស្តែង នៃលេខាធិការដ្ឋាន **គ.ផ.ទ.រ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៧ :_**

**លេខាធិការដ្ឋាន នៃ គ.ផ.ទ.រ.**មានភារកិច្ច ដូចខាងក្រោម៖

- ប្រមូល ពិនិត្យ និងផ្ទៀងផ្ទាត់ ទ្រព្យសម្បត្តិរដ្ឋ និងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដែលជាកម្មវត្ថុនៃការផ្ទេរ
- ចុះពិនិត្យ តាមដាន និងវាយតម្លៃ ទ្រព្យសម្បត្តិរដ្ឋជាក់ស្តែងដែលត្រូវផ្ទេរ ទៅឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋថ្នាក់ក្រោមជាតិ
- ចាត់ចែង និងរៀបចំកិច្ចប្រជុំ **គ.ផ.ទ.រ.**ស្របតាមការណែនាំរបស់ប្រធាន **គ.ផ.ទ.រ.**
- រៀបចំឯកសារ និងកំណត់ហេតុប្រជុំ ដាក់ជូនប្រធាន **គ.ផ.ទ.រ.**
- ផ្តល់យោបល់ និងរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងការស្នើសុំផ្ទេរទ្រព្យសម្បត្តិរដ្ឋជូនប្រធាន **គ.ផ.ទ.រ.**
- បំពេញការងារបន្ថែមទៀតតាមការកំណត់របស់ប្រធាន **គ.ផ.ទ.រ.**។

**ប្រការ៨ :_**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ :_**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១រោច ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០៦២...សហវ.ប្រក.០០៩

**ប្រកាស**
**ស្ដីពី**
**តួនាទីនិងភារកិច្ចរបស់អ្នកត្រួតពិនិត្យថវិកា**
**និងការប្រគល់សិទ្ធិជាអភិបាលថវិកាជូនអ្នកត្រួតពិនិត្យថវិកា**
**ប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកា និងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៥៩ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងថវិកា គណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ ៤១១ សហវ.ប្រក ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៤៥០ សហវ.ប្រក.អថ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ ស្តីពីវិធាននិងនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់តួនាទីនិងភារកិច្ចរបស់អ្នកត្រួតពិនិត្យថវិកា និងសិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់អភិបាលថវិកា ដើម្បីចូលរួមចំណែកជានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការត្រួតពិនិត្យការអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ (**គ.ស.រ.ជ.**) ។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពចំពោះការអនុវត្តថវិការបស់ **គ.ស.រ.ជ.** ។

## ជំពូកទី២
## តួនាទីនិងភារកិច្ចរបស់អ្នកត្រួតពិនិត្យថវិកាប្រចាំ គ.ស.រ.ជ.

**ប្រការ៣.-**

អ្នកត្រួតពិនិត្យថវិកាប្រចាំ **គ.ស.រ.ជ.** មានភារកិច្ច ដូចខាងក្រោម ៖

- អនុវត្តគោលនយោបាយ និងទិសដៅកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធាណៈរបស់រាជរដ្ឋាភិបាល
- បច្ចុប្បន្នភាពចំណេះដឹង និងជំនាញបច្ចេកទេសជាលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ នឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- តាមដានការអនុវត្តគោលនយោបាយរបស់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងកម្មវិធីសកម្មភាពការងាររបស់ **គ.ស.រ.ជ.**



K

- ជានាប្រសិទ្ធភាពនៃការអនុវត្តថវិកា ដោយគោរពឱ្យបានហ្មត់ចត់នូវវិន័យថវិកា គោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- ផ្សព្វផ្សាយ ផ្ដល់យោបល់ ណែនាំអំពីលិខិតបទដ្ឋានគតិយុត្ត នីតិវិធីចំណូល-ចំណាយ ដល់ **គ.ស.រ.ជ.** ក្នុងគោលបំណងលើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពជំនាញគ្រប់គ្រងថវិកានៅ **គ.ស.រ.ជ.**
- តាមដាន និងជំរុញការអនុវត្តចំណូលទាំងអស់របស់ **គ.ស.រ.ជ.**
- ត្រួតពិនិត្យជាមុនអំពីភាពត្រឹមត្រូវនៃការស្នើសុំជានាចំណាយ ផ្ទៀងផ្ទាត់ស្ថានភាពឥណទាន សមតុល្យគណនីប្រាក់បញ្ញើរបស់ **គ.ស.រ.ជ.**
- ផ្ដល់ទិដ្ឋាការលើលិខិតជានាចំណាយ និងលើអាណត្តិបើកប្រាក់តាមមុខសញ្ញាចំណាយ ដូចមានក្នុងប្រការ៥ ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ នៃថ្ងៃធ្វើការ ជូន **គ.ស.រ.ជ.** ដោយអនុលោមតាមវិធាន និងនីតិវិធីហិរញ្ញវត្ថុជាធរមាន
- ផ្ដល់យោបល់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេចលើសំណើសុំជានាចំណាយ សម្រាប់មុខសញ្ញាចំណាយដែលមិនស្ថិតក្រោមសិទ្ធិអំណាចដែលទទួលបាន
- ត្រួតពិនិត្យសំណើ និងលិខិតយុត្តិការភ្ជាប់អាណត្តិបើកប្រាក់របស់ **គ.ស.រ.ជ.**
- ធ្វើការផ្ទៀងផ្ទាត់តួលេខអនុវត្តថវិកាជាប្រចាំ ជាមួយមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់ **គ.ស.រ.ជ.**
- ចូលរួមរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ **គ.ស.រ.ជ.** និងចូលរួមប្រគល់-ទទួលទំនិញ សេវាសំណង់ តាមនីតិវិធីជាធរមាន
- ពិនិត្យនិងផ្ដល់យោបល់លើការស្នើសុំចលនាឥណទាន
- ធ្វើរបាយការណ៍ប្រចាំខែអំពីការសម្រេចទាំងឡាយរបស់ខ្លួន ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រម
- រៀបចំរបាយការណ៍អនុវត្តថវិកា (ចំណូល-ចំណាយថវិកា) ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- ចូលរួមកិច្ចប្រជុំផ្សេងៗដែលពាក់ព័ន្ធនឹងការគ្រប់គ្រងថវិការបស់ **គ.ស.រ.ជ.**
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី៣
## សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អភិបាលថវិកា

**ប្រការ៤.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គឺជាអភិបាលថវិកាដែលមានសិទ្ធិក្នុងការពិនិត្យនិងផ្ដល់ទិដ្ឋាការជានាចំណាយនិងអាណត្តិបើកប្រាក់ និងលើសំណើចំណាយផ្សេងៗរបស់ **គ.ស.រ.ជ.** ។

អ្នកត្រួតពិនិត្យថវិកាប្រចាំ **គ.ស.រ.ជ.** ត្រូវបានការប្រគល់សិទ្ធិជាអភិបាលថវិកាដូចមានចែងក្នុងប្រកាសនេះ ។

**ប្រការ៥.-**

អ្នកត្រួតពិនិត្យថវិកាត្រូវបានប្រគល់សិទ្ធិជាអភិបាលថវិកា ក្នុងការត្រួតពិនិត្យនិងសម្រេចលើមុខងារនិងភារកិច្ច ដូចខាងក្រោម ៖

ក. ផ្ដល់ទិដ្ឋាការជានាចំណាយលើគ្រប់មុខសញ្ញាចំណាយ ដែលមានទឹកប្រាក់អតិបរមាត្រឹមចំនួន ៣០០ លានរៀល



4-

ខ. ផ្តល់ទិដ្ឋាការធានាចំណាយដោយមិនកំណត់ទឹកប្រាក់ ៖

- លើមុខសញ្ញាចំណាយដែលមានរបបកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអាទិ៍បេសកកម្ម សិក្ខាសាលា វគ្គបណ្តុះបណ្តាល ប្រាក់ឧបត្ថម្ភ ប្រាក់កម្រៃ និង
- លើមុខសញ្ញាចំណាយ ជាអាទិ៍ ទឹក អគ្គិសនី ទូរសព្ទ សេវាអ៊ីនធឺណេត ថ្លៃសេវាបញ្ញើប្រៃសណីយ៍ ចំណាយបង់ពន្ធ

គ. ផ្តល់ប្រាក់បុរេប្រទានក្នុងកម្រិតអតិបរមាត្រឹមចំនួន ១៥០លានរៀល សម្រាប់មុខសញ្ញាចំណាយដែលមានលក្ខណៈចាំបាច់និងបន្ទាន់ ក្នុងករណីមានសមតុល្យគ្រប់គ្រាន់ ក្នុងគណនីប្រាក់បញ្ញើរបស់ **គ.ស.ខ.ជ.**នៅរតនាគារជាតិ ឬធនាគារពាណិជ្ជ

ឃ. ផ្តល់ទិដ្ឋាការគ្រប់អាណត្តិបើកប្រាក់របស់ **គ.ស.ខ.ជ.** ដោយពុំកំណត់ចំនួនទឹកប្រាក់ ។

**ប្រការ៦.-**

ក្នុងករណីអ្នកត្រួតពិនិត្យថវិកា ពិនិត្យឃើញថា សំណើចំណាយថវិកានៅក្រោមសិទ្ធិទាំងឡាយមានវេទយិតភាព ត្រូវស្នើសុំការពិនិត្យនិងសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមឋានានុក្រម ។

**ប្រការ៧.-**

អ្នកត្រួតពិនិត្យថវិកា ត្រូវស្នើសុំការសម្រេចពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះមុខសញ្ញាចំណាយ ដែលមិនបានកំណត់ក្នុងប្រការ៥ នៃប្រកាសនេះ ។

**ប្រការ៨.-**

មិនអនុញ្ញាតឱ្យធ្វើការបំបែកគម្រោងចំណាយ ដើម្បីតម្រូវទៅតាមកម្រិតទឹកប្រាក់ដែលបានប្រគល់សិទ្ធិ ។

**ប្រការ៩.-**

ក្នុងករណី អ្នកត្រួតពិនិត្យថវិកាប្រចាំ **គ.ស.ខ.ជ.** អវត្តមានឬមានធុរៈ នាយកដ្ឋានហិរញ្ញកិច្ច នៃអគ្គនាយកដ្ឋានថវិកា ត្រូវរៀបចំការប្រគល់សិទ្ធិជូនមន្ត្រីក្រោមឱវាទមួយរូប ដោយមានការឯកភាពពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទទួលភារកិច្ច ក្នុងការគ្រប់គ្រងចាត់ចែងការងារ និងចុះហត្ថលេខាលើលិខិតផ្លូវការទាំងឡាយ ដើម្បីធានានិរន្តរភាពការងារ ។

**ប្រការ១០.-**

ក្នុងការបំពេញមុខងារតាមការប្រគល់សិទ្ធិខាងលើ អ្នកត្រួតពិនិត្យថវិកា មានសិទ្ធិប្រើប្រាស់ត្រាអភិបាលថវិការបស់នាយកដ្ឋានហិរញ្ញកិច្ច នៃអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ១១.-**

អ្នកត្រួតពិនិត្យថវិកា ត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវរាល់កិច្ចការរបស់ខ្លួន ។

## ជំពូកទី៤
## ទណ្ឌកម្ម

**ប្រការ១២.-**

អភិបាលថវិកា និងអ្នកត្រួតពិនិត្យថវិកា ត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដោយមិនគិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណី ចំពោះសកម្មភាពដែលបានប្រព្រឹត្ត ឬសមគំនិតក្នុងការប្រព្រឹត្ត ។ អនុលោមតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ទណ្ឌកម្មរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល រួមមានជាអាទិ៍ ៖

- ការស្តីបន្ទោស
- ការផ្លាស់កន្លែងធ្វើការដោយបង្ខំតាមវិធានការខាងវិន័យ
- ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យនៅទំនេរគ្មានបៀវត្ស
- ការបន្ថយឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យចូលនិវត្តន៍មុនកំណត់
- ការបញ្ឈប់ពីការងារដោយបង្ខំ ឬការបណ្តេញចេញពីមុខតំណែងជាមន្ត្រីរាជការ ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ១៣.-**

ប្រកាសលេខ ១៧២ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ១៤.-**

អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាយក **គ.ស.រ.ជ.** និងមន្ត្រីត្រួតពិនិត្យថវិកាប្រចាំ **គ.ស.រ.ជ.** ទាំងអស់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃពុធ ១២កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល លេខ 1161
ថ្ងៃទី 02 ខែ 03 ឆ្នាំ 26
ម៉ោង 10H16

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ
លេខ ១៦១ សហវ.ប្រក.អមផ

# ប្រកាសអន្តរក្រសួង
## ស្តីពី
## បែបបទ និងនីតិវិធីនៃការដាក់ពិន័យចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៥.នស.៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨២២/០១០ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០០៩ ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia



ទូរស័ព្ទ: (+៨៥៥) ២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៦២ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ចំណុះក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ ស្ដីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្ដុំ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ ._**

ការផាកពិន័យចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្ដុំ ដែលបានកំណត់ក្នុងមាត្រា១៩ និងមាត្រា២០ នៃអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ ស្ដីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្ដុំ ត្រូវអនុវត្តដូចខាងក្រោម ៖

១- ផាកពិន័យជាប្រាក់ចំនួន ៤០០.០០០(បួនសែន)រៀល ក្នុងករណីធ្វេសប្រហែសខកខានមិនបានបំពេញកាតព្វកិច្ច ដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ ស្ដីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្ដុំ រួមមាន៖
   - មិនបានផ្ដល់ប្លង់ប្រព័ន្ធសន្តិសុខសុវត្ថិភាពនៃអគារស្នាក់នៅក្នុងទីតាំងរស់នៅប្រមូលផ្ដុំ ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន ដល់អាជ្ញាធរមានសមត្ថកិច្ចតាមការស្នើសុំ។
   - មិនបានថែរក្សាឱ្យបានហ្មត់ចត់នូវគុណភាពប្រព័ន្ធសន្តិសុខសុវត្ថិភាពនៃអគារស្នាក់នៅ និង/ឬបរិវេណនៃទីតាំងរស់នៅប្រមូលផ្ដុំ ឱ្យបានត្រឹមត្រូវតាមនិយាមបច្ចេកទេស។
   - មិនបានអនុវត្តតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច ក្នុងការកែលម្អប្រព័ន្ធការពារសន្តិសុខ។

២- ផាកពិន័យជាប្រាក់ចំនួន ៤.០០០.០០០(បួនលាន)រៀល សម្រាប់ជនបរទេសម្នាក់ ក្នុងករណីមានចេតនាលាក់បាំង និងអនុញ្ញាតឱ្យជនបរទេសនោះ ដែលចូលមកព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ស្នាក់នៅក្នុងទីតាំងស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន។

**ប្រការ២ ._**

ការអនុវត្តការផាកពិន័យដូចមានចែងនៅក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ ត្រូវប្រគល់ភារកិច្ចជូនមន្ត្រីនគរបាលនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត។

**ប្រការ៣ ._**

មន្ត្រីនគរបាលដែលមានសមត្ថកិច្ចផាកពិន័យ ត្រូវចេញបង្កាន់ដៃផាកពិន័យចំនួនមួយច្បាប់ប្រគល់ជូនទៅបុគ្គលដែលត្រូវទទួលរងការផាកពិន័យ ទៅតាមករណីដូចមានចែងក្នុងប្រការ១ នៃប្រកាសអន្តរក្រសួងនេះ។ ទម្រង់គំរូបង្កាន់ដៃផាកពិន័យ មានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៤ ._**

បុគ្គលដែលទទួលរងការផាកពិន័យ ត្រូវទៅបង់ប្រាក់ពិន័យនៅការិយាល័យគណនេយ្យនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្តសាមី ឬផ្ទេរទឹកប្រាក់ពិន័យចូលក្នុងគណនីធនាគារដែលបានកំណត់ក្នុងបង្កាន់ដៃផាកពិន័យក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលបង្កាន់ដៃផាកពិន័យ។

ករណីទទួលប្រាក់ពិន័យដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានបត្រ មន្ត្រីមុខការនៃការិយាល័យគណនេយ្យត្រូវចេញបង្កាន់ដៃបង់ប្រាក់ចំនួនមួយច្បាប់ប្រគល់ជូនទៅអ្នកបង់ប្រាក់ ដោយប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបោះពុម្ព និងបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្នុងករណីមានការយឺតយ៉ាវ ឬមិនបានបង់ប្រាក់ពិន័យក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ ដែលបានកំណត់ នោះបុគ្គលដែលទទួលរងការផាកពិន័យនឹងត្រូវទទួលរងការផាកពិន័យចំនួន ២% បន្ថែមទៀត លើប្រាក់ផាកពិន័យដើម។

ក្នុងករណីបុគ្គលដែលទទួលរងការផាកពិន័យ មានការរឹងរូសមិនព្រមបង់ប្រាក់ផាកពិន័យក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលបង្កាន់ដៃផាកពិន័យ នោះមន្ត្រីមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងបញ្ជូនទៅសាលាជម្រះក្តីមានសមត្ថកិច្ច ដើម្បីចាត់ការទៅតាមនីតិវិធីនៃច្បាប់។

**ប្រការ៥ .-**

ជារៀងរាល់ខែ ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវវេរសរាន់បង់ប្រាក់ចំណូលដែលប្រមូលបានពីការផាកពិន័យ ទៅអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ ស្របតាមនីតិវិធីជាធរមាន ដើម្បីធ្វើការបែងចែក និងចាត់ចែងបង់ចំណូលចូលថវិកាជាតិឱ្យបានទាន់ពេលវេលា ស្របតាមគោលការណ៍ដែលបានកំណត់។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

អគ្គលេខាធិការ អគ្គស្នងការនគរបាលជាតិ អគ្គនាយក អគ្គាធិការ និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អភិសន្តិបណ្ឌិត ស សុខា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងលេខ១៦១......សហវ.ប្រក.អទច ចុះថ្ងៃទី២៥.. ខែ[illegible] ឆ្នាំ២០២៦**
**ស្ដីពីបែបបទ និងនីតិវិធីនៃការផាកពិន័យចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**
អគ្គស្នងការដ្ឋាននគរបាលជាតិ
ស្នងការដ្ឋាននគរបាល..........
លេខ................................

## បង្កាន់ដៃផាកពិន័យ

យើង................................................ អត្តលេខ.................... ទូរសព្ទលេខ............................... ជាមន្ត្រីនគរបាល បម្រើការងារនៅ.................................................... បានត្រួតពិនិត្យលើទីតាំងរស់នៅប្រមូលផ្តុំមួយកន្លែង ជាប្រភេទ ................................ ដែលមានអាសយដ្ឋានលេខ.......... ផ្លូវ........ ភូមិ.................. ឃុំ/សង្កាត់......................... ក្រុង/ស្រុក/ខណ្ឌ.................................... រាជធានី/ខេត្ត........................................ ដែលមានម្ចាស់ ឬអ្នកគ្រប់គ្រង ឈ្មោះ......................................... ភេទ.......... ជនជាតិ............................. កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ................................. ស្នាក់នៅអាសយដ្ឋានផ្ទះលេខ.......... ផ្លូវ............. ភូមិ......................... ឃុំ/សង្កាត់............................. ក្រុង/ស្រុក/ខណ្ឌ.................................... រាជធានី/ខេត្ត.................................. ទូរសព្ទលេខ..................................បានប្រព្រឹត្តល្មើសនឹងមាត្រា............. នៃអនុក្រឹត្យលេខ០៣ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០២៦ ស្ដីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ ត្រូវទទួលរងការផាកពិន័យចំនួន ......................................(......................................................) រៀល។

សូមអញ្ជើញទៅបង់ប្រាក់ផាកពិន័យនៅការិយាល័យគណនេយ្យនៃស្នងការដ្ឋាននគរបាល......................................... ឬ ផ្ទេរទឹកប្រាក់ពិន័យចូលគណនីឈ្មោះ................................ លេខគណនី......................... នៅធនាគារ..........................។

**បញ្ជាក់៖**
- ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំដែលបានប្រព្រឹត្តអំពើល្មើស ត្រូវបង់ ឬផ្ទេរទឹកប្រាក់ផាកពិន័យក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលបង្កាន់ដៃផាកពិន័យនេះ។
- ក្នុងករណីមានការយឺតយ៉ាវ ឬមិនបានបង់ប្រាក់ពិន័យក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ នឹងត្រូវទទួលរងការផាកពិន័យចំនួន ២% បន្ថែមទៀត លើប្រាក់ផាកពិន័យដើម។
- ក្នុងករណីបុគ្គលដែលទទួលរងការផាកពិន័យ មានការរឹងរូសមិនព្រមបង់ប្រាក់ផាកពិន័យក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលបង្កាន់ដៃផាកពិន័យ នោះមន្ត្រីមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងបញ្ជូនទៅសាលាជម្រះក្តីមានសមត្ថកិច្ច ដើម្បីចាត់ការទៅតាមនីតិវិធីនៃច្បាប់។
- បង្កាន់ដៃផាកពិន័យនេះ ជាប្រភេទបង្កាន់ដៃប្រើសម្រាប់ដាក់បន្ទុកផាកពិន័យចំពោះម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ ដែលទទួលរងការផាកពិន័យប៉ុណ្ណោះ មិនមែនជាប្រភេទបង្កាន់ដៃដែលបញ្ជាក់ថាបានបង់ ឬបានទទួលប្រាក់ផាកពិន័យនោះទេ។៚

ធ្វើនៅ............................ ថ្ងៃទី....... ខែ............ ឆ្នាំ២០....

**ស្នាមមេដៃស្តាំ** **ហត្ថលេខាមន្ត្រីនគរបាល**
**ម្ចាស់ ឬអ្នកគ្រប់គ្រងទីតាំងរស់នៅប្រមូលផ្តុំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៦ សហវ.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងាររៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការកែសម្រួល មាត្រា ៥០ មាត្រា ៥១ មាត្រា ៥២ និងមាត្រា ៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្តីពីការបង្កើត និង បំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យស្ថិតនៅក្រោមឱវាទក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

បង្កើត "ក្រុមការងាររៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការថែទាំហេដ្ឋារចនា សម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធជាពសាស្ត្រ" នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **រស់ បរម** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តម **ឈួន សំរិទ្ធិ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-ឯកឧត្តម **ស៊ឹម វីរៈ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤-ឯកឧត្តម **ហាវ រតនៈ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា(អ.ថ.) | អនុប្រធាន |
| ៥-ឯកឧត្តម **វង្ស ម៉ុនឥន្ទ្រាវុធ** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៦-ឯកឧត្តម **ហ៊ុល បុណ្ណារ័ត្ន** | អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | សមាជិក |
| ៧-លោក **វន្សី វិចិត្រ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ៨-លោក **ហ៊ីង ច័ន្ទបូរ៉ា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាល ថ្នាក់ក្រោមជាតិ | សមាជិក |
| ៩-លោក **មិញ បានសុវណ្ណ អាទិច្ចាសីលា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ១០-លោក **ហួត វឌ្ឍនា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ១១- លោក **ណុំ ស៊ីនិត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូល មិនមែនសារពើពន្ធ (អ.ទ.ច) | សមាជិក |
| ១២- លោក **ហៀង វុឌ្ឍិភា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជន (អ.រ.ជ) | សមាជិក |
| ១៣-លោក **ឈាង យូ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ១៤- លោក **អៀង សេដ្ឋា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល | សមាជិក |
| ១៥-លោក **ឡាយ សុភ័ក្ត្រ** | ប្រធាននាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |

| | | |
|---|---|---|
| ១៦-លោក **យ៉ន សម្បត្តិ** | ប្រធាននាយកដ្ឋានប្រសិទ្ធភាពចំណាយ នៃអគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៧-លោក **ហៃ សុខុធ្វា** | ប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ១៨-លោក **ណិប សំផុន** | ប្រធាននាយកដ្ឋានគ្រប់គ្រងលទ្ធកម្មសាធារណៈ នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ១៩-លោក **សុខ ធី** | ប្រធាននាយកដ្ឋានសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ នៃអ.ទ.ច | សមាជិក |
| ២០-លោក **ម៉ែន វិបុលសក្តិ** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍គម្រោង នៃអ.រ.ជ | សមាជិក |
| ២១-លោក **យ៉ង់ ស៊ី** | អនុប្រធាននាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ២២-លោក **កែម ចាន់ឡើន** | ប្រធានការិយាល័យថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ នៃនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ២៣-លោកស្រី **ជួន ចាន់ណា** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ២៤-លោក **ប្រាក់ វណ្ណាដេត** | អនុប្រធានការិយាល័យថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ នៃនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ២៥-លោក **ហៀង សុយ៉ារ៉ូ** | មន្ត្រីជំនាញជាន់ខ្ពស់ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ២៦-លោក **ស៊ិន ហៀង** | មន្ត្រីជំនាញ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សមាជិក។ |

**ប្រការ២.-**

ក្រុមការងាររៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវអំពីឧត្តមានុវត្តន៍អន្តរជាតិ និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ
- ដឹកនាំការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ
- ដឹកនាំ និងសម្របសម្រួលកិច្ចប្រជុំពិគ្រោះយោបល់ជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ, អគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍពាក់ព័ន្ធ ដើម្បីពិនិត្យ ពិភាក្សា និងប្រមូលធាតុចូល ដើម្បីជាមូលដ្ឋានក្នុងការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រកែទម្រង់
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃយុទ្ធសាស្ត្រការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ និងស្នើសុំអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការចាំបាច់
- ផ្សព្វផ្សាយយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធ

ជាពាសាស្ត្រ បន្ទាប់ពីទទួលបានការអនុម័តពីប្រមុខរាជរដ្ឋាភិបាល

- ត្រួតពិនិត្យ និងតាមដានការអនុវត្តយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធជាពាសាស្ត្រ ដើម្បីធ្វើបច្ចុប្បន្នភាពលើយុទ្ធសាស្ត្រកែទម្រង់ ឱ្យសមស្របតាមបរិបទជាក់ស្តែង
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

ក្រុមការងាររៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធជាពាសាស្ត្រ មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១-លោក **ខឡី ទិចិត្រ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា(អ.ថ.) | ប្រធាន |
| ២-លោក **ឡាយ សុភ័ក្ត្រ** | ប្រធាននាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា | អនុប្រធាន |
| ៣-លោក **យ៉េ ស៊ី** | អនុប្រធាននាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ៤-លោក **កែម ចាន់ឌឿន** | ប្រធានការិយាល័យថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ នៃនាយកដ្ឋានវិនិយោគ នៃអ.ថ | សមាជិក |
| ៥-លោក **ប្រាក់ វណ្ណាដេត** | អនុប្រធានការិយាល័យថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ នៃនាយកដ្ឋានវិនិយោគ នៃអ.ថ | សមាជិក |
| ៦-លោកស្រី **ទិត ដាឡែន** | មន្ត្រីការិយាល័យថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈនៃនាយកដ្ឋានវិនិយោគ នៃអ.ថ. | សមាជិកា |
| ៧-កញ្ញា **គូ សូលីតា** | មន្ត្រីជាប់កិច្ចសន្យា នៃនាយកដ្ឋានវិនិយោគ នៃអ.ថ. | សមាជិកា |
| ៨-លោក **ខុច ពុទ្ធិវិទ្យា** | បុគ្គលិកកិច្ចសន្យា នៃនាយកដ្ឋានវិនិយោគ នៃអ.ថ. | សមាជិក |
| ៩-លោក **សុគន្ធ វិរៈស័ក** | បុគ្គលិកកិច្ចសន្យា នៃនាយកដ្ឋានវិនិយោគ នៃអ.ថ. | សមាជិក។ |

**ប្រការ៤ .-**

លេខាធិការដ្ឋាន នៃក្រុមការងាររៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធជាពាសាស្ត្រ មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- សិក្សា ស្រាវជ្រាវ ប្រមូល និងចងក្រងព័ត៌មានពាក់ព័ន្ធ ក្នុងការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធជាពាសាស្ត្រ
- រៀបចំកិច្ចប្រជុំពិគ្រោះយោបល់កម្រិតបច្ចេកទេសជាមួយនឹងក្រសួង-ស្ថាប័នពាក់ព័ន្ធ, អគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ
- ពិនិត្យ និងកែសម្រួលលើសេចក្តីព្រាងយុទ្ធសាស្ត្រពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងប្រព័ន្ធជាពាសាស្ត្រ ក្រោយកិច្ចប្រជុំ ឬពិគ្រោះយោបល់ជាមួយអង្គភាព ស្ថាប័នពាក់ព័ន្ធ និងអ្នកជំនាញការបច្ចេកទេសនានា
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការរៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ និងលើកបញ្ហាប្រឈមនានា និងដំណោះស្រាយ ដាក់ជូនប្រធានក្រុមការងាររៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ ដើម្បីពិនិត្យ សម្រេច និងផ្តល់ការណែនាំជាយថាហេតុ

- អាចស្នើសុំបំពេញទស្សនកិច្ចសិក្សា ចូលរួមសិក្ខាសាលា ឬ វគ្គបណ្តុះបណ្តាល ឬជ្រើសរើសទីប្រឹក្សា ដើម្បីបំពេញការងារឱ្យក្រុមការងាររៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ ក្នុងករណីចាំបាច់ណាមួយ
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់របស់ប្រធានក្រុមការងាររៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ។

**ប្រការ៥ .-**

អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធានក្រុមការងាររៀបចំសេចក្តីព្រាងយុទ្ធសាស្ត្រ។

ប្រធានក្រុមការងារ អាចអញ្ជើញថ្នាក់ដឹកនាំ ឬមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ចូលរួមប្រជុំ តាមការចាំបាច់។

ក្នុងករណីអវត្តមាន ប្រធានក្រុមការងារអាចចាត់តាំងអនុប្រធាន ១ រូប ដើម្បីសម្របសម្រួលដឹកនាំកិច្ចប្រជុំជំនួស។

**ប្រការ៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋាន ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ និងប្រការ៣ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១២កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមករា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ដូចប្រការ៧ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៦៦......សហវ.

ទីស្ដីការគណៈរដ្ឋមន្ត្រី
ចូល
លេខ 1250
ថ្ងៃទី 06 ខែ 03 ឆ្នាំ 26
ម៉ោង 10ᴴ08

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំកំណត់ទុនគ្រាដំបូងរបស់មូលនិធិជាតិជំនួយសង្គម ដែលត្រូវបានបង្កើតជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ២៥៩ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការគ្រប់គ្រងថវិកា គណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២២ ស្តីពីការបង្កើតមូលនិធិជាតិជំនួយសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញសេចក្តីសម្រេចលេខ ១០០ សសរ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យអនុវត្តគំរូអនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញលិខិតលេខ ៣១១៧ ស.អ.យ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីសំណើសុំធ្វើបច្ចុប្បន្នភាពថ្មីនៃគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំកំណត់ទុនគ្រាដំបូងរបស់មូលនិធិជាតិជំនួយសង្គម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**សម្រេច**

**ប្រការ ១.**_

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក.សហវ), ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រសួង ស.អ.យ.) និងមូលនិធិជាតិជំនួយសង្គម (ម.ជ.ជ.) ដើម្បីរៀបចំកំណត់ទុនគ្រាដំបូងរបស់ ម.ជ.ជ. ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ប្រាក់ សុខឃួរ** | រដ្ឋលេខាធិការប្រចាំការ នៃ ក្រសួង ស.អ.យ. | ប្រធាន |
| ២. ឯកឧត្តម | **ម៉ែន ឧត្ដា** | អនុរដ្ឋលេខាធិការ នៃ ក.សហវ | អនុប្រធាន |
| ៣. ឯកឧត្តម | **ស៊ឹម សុធន** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃ ម.ជ.ជ. | អនុប្រធាន |
| ៤. ឯកឧត្តម | **ទៀន រិទ្ធីរ័ត្ន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ នៃ ក្រសួង ស.អ.យ. | សមាជិក |

| | | | | |
|---|---|---|---|---|
| ៥. | ឯកឧត្តម | **ទួន សំបូរ** | អគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (អ.ទ.ប) | សមាជិក |
| ៦. | លោក | **ប៉ាវ សុផល** | អគ្គនាយករង នៃ អ.ទ.ប | សមាជិក |
| ៧. | លោកជំទាវ | **អ៊ុយ ច័ន្ទនិមល** | អគ្គនាយករងទទួលបន្ទុកការងារគណនេយ្យ និងហិរញ្ញវត្ថុ នៃ ម.ជ.ជ. | សមាជិក |
| ៨. | លោក | **វណ្ណា សំណាង** | ប្រធាននាយកដ្ឋានសហគ្រាសសាធារណៈ នៃ អ.ទ.ប | សមាជិក |
| ៩. | លោក | **យស់ សំអុល** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ នៃ ក្រសួង ស.អ.យ. | សមាជិក |
| ១០. | លោក | **ស្នួន ឌីណោ** | ប្រធាននាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ នៃ ម.ជ.ជ. | សមាជិក |
| ១១. | លោក | **ដេត វាសនា** | អនុប្រធាននាយកដ្ឋានសហគ្រាសសាធារណៈ នៃ អ.ទ.ប | សមាជិក |
| ១២. | លោក | **ស្វូរ សារិទ្ធ** | អនុប្រធាននាយកដ្ឋានសហគ្រាសសាធារណៈ នៃ អ.ទ.ប | សមាជិក |
| ១៣. | លោក | **ស្វាយ គុណ្ណាវុទ្ធ** | អនុប្រធាននាយកដ្ឋានសហគ្រាសសាធារណៈ នៃ អ.ទ.ប | សមាជិក |
| ១៤. | លោក | **ហេង វឌ្ឍធីរិទ្ធ** | គណនេយ្យករ នៃ ម.ជ.ជ. | សមាជិក |
| ១៥. | លោកស្រី | **ឃី សុខគា** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ នៃ ម.ជ.ជ. | សមាជិក |
| ១៦. | លោក | **ហុង សុវណ្ណដារ៉ា** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ នៃ ម.ជ.ជ. | សមាជិក |
| ១៧. | លោកស្រី | **សាយ ច័ន្ទភញ្ញា** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ នៃ ម.ជ.ជ. | សមាជិក |
| ១៨. | លោក | **ស៊ីន សារ៉ាំ** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងថវិកា ហិរញ្ញវត្ថុ និងគណនេយ្យ នៃ ម.ជ.ជ. | សមាជិក |
| ១៩. | លោកស្រី | **គួ រឌ្យី** | ប្រធានការិយាល័យសហគ្រាសសាធារណៈ នៃ អ.ទ.ប | សមាជិក |
| ២០. | លោក | **សេង សុជាតិ** | ប្រធានការិយាល័យគ្រឹះស្ថានសាធារណៈរដ្ឋបាល នៃ អ.ទ.ប | សមាជិក |
| ២១. | លោក | **ម៉ិត ផៃ** | មន្ត្រីត្រួតពិនិត្យថវិកាប្រចាំ ម.ជ.ជ. | សមាជិក |
| ២២. | លោក | **សុភ សុផាន់ណា** | ប្រធានការិយាល័យថវិកា និងហិរញ្ញវត្ថុ នៃ ម.ជ.ជ. | សមាជិក |
| ២៣. | លោកស្រី | **ហោ លីហ៊ា** | ប្រធានការិយាល័យគណនេយ្យ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៃ ម.ជ.ជ. | សមាជិក។ |

**ប្រការ ២.**_

គណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំកំណត់ទុនគ្រាដំបូងរបស់មូលនិធិជាតិជំនួយសង្គម ក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានភារកិច្ចចុះធ្វើសារពើភណ្ឌ ត្រួតពិនិត្យ និងវាយតម្លៃឡើងវិញនូវចលនទ្រព្យ និងអចលនទ្រព្យ ស្ថានភាពឥណទេយ្យ បំណុល រតនវត្ថុ និងទ្រព្យសម្បត្តិផ្សេងទៀតទាំងអស់របស់មូលនិធិជាតិជំនួយសង្គម ដោយសហការជាមួយក្រុមការងារបច្ចេកទេសរបស់មូលនិធិជាតិជំនួយសង្គមផ្ទាល់ ដើម្បីរៀបចំតារាងតុល្យការចាប់ផ្តើមកំណត់ទុនគ្រាដំបូង ទុកភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងអនុក្រឹត្យនៃការបង្កើតរបស់ខ្លួន។

**ប្រការ ៣.**_

សមាសភាពគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំកំណត់ទុនគ្រាដំបូងរបស់មូលនិធិជាតិជំនួយសង្គម ក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវចូលរួមប្រជុំតាមតម្រូវការការងារជាក់ស្តែងរបស់គណៈកម្មការ។

គណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំកំណត់ទុនគ្រាដំបូងរបស់មូលនិធិជាតិជំនួយសង្គម មានសិទ្ធិអញ្ជើញអគ្គនាយក ព្រមទាំងមន្ត្រីពាក់ព័ន្ធផ្សេងៗទៀតនៃមូលនិធិជាតិជំនួយសង្គម ក៏ដូចជាអង្គភាពពាក់ព័ន្ធនៃក្រសួងអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ ៤.**_

រាល់សេចក្តីសម្រេចដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥.**_

អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ២កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល
លេខ 1547
ថ្ងៃទី 19 ខែ 03 ឆ្នាំ 26
ម៉ោង 4H 54

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
លេខ៖ ០៤០ ឧវ.អន.ប្រក.

# ប្រកាសអន្តរក្រសួង
# ស្តីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ**
**បច្ចេកវិទ្យា និងនវានុវត្តន៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើប្រាស់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៥ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសារពើពន្ធ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ស្ដីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ស្ដីពីការកែសម្រួល មាត្រា៥០ មាត្រា៥១ មាត្រា៥២ និងមាត្រា៥៣ នៃអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការបង្កើត និងការបំពេញបន្ថែមអគ្គនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ ១៤១ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ ស្ដីពីការបង្កើតមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្ដីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៥៩ អនក្រ បក. ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការគ្រប់គ្រងថវិកាគណនេយ្យ និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ

- បានឃើញអនុក្រឹត្យលេខ ២៦៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៥ ស្តីពីការរៀបចំអង្គភាពសវនកម្មផ្ទៃក្នុងក្រសួង ស្ថាប័ន ចំណុះអង្គការនីតិប្រតិបត្តិ
- បានឃើញប្រកាសលេខ ៤៥០ សហវ.ប្រក. អថ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥ ស្តីពីវិធាននិងនីតិវិធីអនុវត្តថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលថ្នាក់ជាតិ
- បានឃើញអនុក្រឹត្យលេខ ១៣២ អនក្រ.បក ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដែលសរសេរជាអក្សរកាត់ថា **ម.ជ.វ.ប.ន.**។

## ជំពូកទី២
## រចនាសម្ព័ន្ធនិងភារកិច្ច

### ផ្នែកទី១
### រចនាសម្ព័ន្ធ

**ប្រការ២.-**

**ម.ជ.វ.ប.ន.**មានរចនាសម្ព័ន្ធចំណុះ ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាលនិងធនធានមនុស្ស
- ការិយាល័យហិរញ្ញវត្ថុ
- ការិយាល័យស្រាវជ្រាវនិងអភិវឌ្ឍអាជីវកម្ម
- មន្ទីរពិសោធន៍មីក្រូជីវសាស្ត្រ
- មន្ទីរពិសោធន៍គីមីសាស្ត្រទឹក
- មន្ទីរពិសោធន៍គីមីសាស្ត្រម្ហូបអាហារ
- មន្ទីរពិសោធន៍គីមីសាស្ត្រមិនមែនម្ហូបអាហារ
- មន្ទីរពិសោធន៍មេកានិក អគ្គិសនី និងអេឡិចត្រូនិក។

**ម.ជ.វ.ប.ន.** មានគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មជាសេនាធិការឱ្យនាយក **ម.ជ.វ.ប.ន.** និងទទួលខុសត្រូវលើការគ្រប់គ្រងនិងអនុវត្តលទ្ធកម្មសាធារណៈដែលត្រូវបង្កើតឡើង និងមានតួនាទី ភារកិច្ច អនុលោម

តាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ អង្គភាពលទ្ធកម្ម មានតួនាទីជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការលទ្ធកម្ម។

**ម.ជ.វ.ប.ន.** មានគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជាសេនាធិការឱ្យនាយក **ម.ជ.វ.ប.ន.** និងទទួលខុសត្រូវលើការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវបង្កើតឡើងអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខនៃរចនាសម្ព័ន្ធរបស់ **ម.ជ.វ.ប.ន.** ជាឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ។

**ប្រការ៣.-**

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មន្ទីរពិសោធន៍នីមួយៗត្រូវដឹកនាំដោយប្រធានមន្ទីរពិសោធន៍ ១(មួយ) រូប និងមានអនុប្រធានមន្ទីរពិសោធន៍មួយចំនួនតាមការចាំបាច់ ដោយអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ប្រធានការិយាល័យ ប្រធានមន្ទីរពិសោធន៍ អនុប្រធានការិយាល័យ និងអនុប្រធានមន្ទីរពិសោធន៍ ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ពីមុខតំណែង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមសំណើរបស់នាយក **ម.ជ.វ.ប.ន.** ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល **ម.ជ.វ.ប.ន.**។

## ជំពូកទី២
## ភារកិច្ចរបស់ការិយាល័យនិងអង្គភាពចំណុះនៃ ម.ជ.វ.ប.ន.

**ប្រការ៤.-**

ការិយាល័យរដ្ឋបាលនិងធនធានមនុស្ស មានភារកិច្ចដូចខាងក្រោម៖

- ចាត់ចែង គ្រប់គ្រងលិខិតស្នាមចេញ ចូលគ្រប់ប្រភេទ និងបែងចែកលិខិតទាំងនោះទៅតាមទម្រង់និងបែបបទរដ្ឋបាលនិងតម្កល់ឯកសារទុកក្នុង **ម.ជ.វ.ប.ន.**
- គ្រប់គ្រង ថែទាំ ជួសជុល ចលនទ្រព្យ និងអចលនទ្រព្យ គ្រប់ប្រភេទរបស់ **ម.ជ.វ.ប.ន.**
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ជួយសម្រួលដល់ការងារគ្រប់គ្រងរបស់ **ម.ជ.វ.ប.ន.**
- គ្រប់គ្រង អភិវឌ្ឍន៍ ទិន្នន័យព័ត៌មានវិទ្យា គេហទំព័រ និងប្រព័ន្ធផ្សព្វផ្សាយរបស់ **ម.ជ.វ.ប.ន.**
- រៀបចំចេញវិញ្ញាបនបត្រនិងរបាយការណ៍ធ្វើតេស្តវិភាគ របស់ **ម.ជ.វ.ប.ន.**
- រៀបចំលក្ខន្តិកៈព័ត៌មាន បទបញ្ជាផ្ទៃក្នុង និងវិធានផ្ទៃក្នុង ព្រមទាំងស្តង់ដាប្រតិបត្តិនានាសម្រាប់ដំណើរការរបស់ **ម.ជ.វ.ប.ន.**
- រៀបចំរាល់លិខិតបទដ្ឋានមានជាអាទិ៍ ការតែងតាំង ការតាំងស៊ប់ ការផ្លាស់ប្តូរកន្លែងធ្វើការ ការដាក់ពិន័យ ការដាក់ឱ្យនៅក្រៅក្របខ័ណ្ឌដើម ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស និងការលុបឈ្មោះចេញពីក្របខ័ណ្ឌ
- រៀបចំផ្តល់អត្ថប្រយោជន៍បន្ថែមដោយអនុលោមទៅតាមគោលការណ៍និងនីតិវិធីដែលអាចមានការប្រែប្រួលយោងទៅតាមសមិទ្ធផលការងារនិងការសម្រេចរបស់គណៈគ្រប់គ្រងគ្រឹះស្ថាន
- រៀបចំនិងសម្របសម្រួលលើការបណ្តុះបណ្តាល សិក្ខាសាលា និងការងារពិធីការ
- គ្រប់គ្រងព័ត៌មានមន្ត្រីនិងបុគ្គលិកទាំងអស់របស់ **ម.ជ.វ.ប.ន.**
- តាមដានត្រួតពិនិត្យសុវត្ថិភាពក្នុងបរិវេណ **ម.ជ.វ.ប.ន.**
- បូកសរុបរបាយការណ៍ជូននាយក **ម.ជ.វ.ប.ន.**
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយក **ម.ជ.វ.ប.ន.**។

**ប្រការ៥.-**

ការិយាល័យហិរញ្ញវត្ថុ មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការអភិវឌ្ឍន៍ គម្រោងថវិកាប្រចាំឆ្នាំ និងគម្រោងវិនិយោគរបស់ **ម.ជ.វ.ប.ន.**
- គ្រប់គ្រងការប្រមូលចំណូលដែលទទួលបានពីការផ្តល់សេវាតេស្តវិភាគនិងចំណូលផ្សេងៗ
- គ្រប់គ្រងនិងចាត់ចែងការអនុវត្តថវិកា ស្របតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន
- រៀបចំលិខិតបទដ្ឋានស្តង់ដារប្រតិបត្តិសម្រាប់ការគ្រប់គ្រងថវិកាទៅតាមតម្រូវការរបស់ **ម.ជ.វ.ប.ន.**
- គ្រប់គ្រងនិងអភិវឌ្ឍការអនុវត្តការងារហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS)
- ធ្វើការទំនាក់ទំនងជាមួយក្រសួងអាណាព្យាបាលទាំងពីរពាក់ព័ន្ធនឹងការរៀបចំការអនុវត្ត និងគ្រប់គ្រងថវិកា ស្របតាមគោលការណ៍ហិរញ្ញវត្ថុ ព្រមទាំងតាមដានលទ្ធផលនៃការអនុវត្តថវិកា
- គ្រប់គ្រង ពិនិត្យតាមដានស្ថានភាពឥណទាន លើកសំណើសុំគោលការណ៍ចលនាឥណទាន និងចាត់ចែងការអនុវត្តថវិកា ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន
- សម្របសម្រួលក្នុងនាមជាសេនាធិការ របស់នាយក ម.ជ.វ.ប.ន. សម្រាប់ការតាមដាន ត្រួតពិនិត្យ ការធ្វើអធិការកិច្ច និងសវនកម្ម
- រៀបចំរបាយការណ៍ចំណូលនិងចំណាយថវិកា ប្រចាំខែ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ព្រមទាំងរបាយការណ៍សមិទ្ធកម្មរបស់ **ម.ជ.វ.ប.ន.** ប្រចាំឆមាស និងប្រចាំឆ្នាំជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត មុននឹងផ្ញើជូនក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ត្រួតពិនិត្យនិងតម្កល់ទុកឯកសារ និងរបាយការណ៍គណនេយ្យ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារ រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងរបាយការណ៍គ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ **ម.ជ.វ.ប.ន.**
- គ្រប់គ្រងឃ្លាំងសម្ភារការិយាល័យអនាម័យ ឃ្លាំងប្រតិករ និងឃ្លាំងផ្សេងៗទៀត
- បូកសរុបរបាយការណ៍ជូននាយក **ម.ជ.វ.ប.ន.**
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយក **ម.ជ.វ.ប.ន.**។

**ប្រការ៦.-**

ការិយាល័យស្រាវជ្រាវនិងអភិវឌ្ឍន៍អាជីវកម្ម មានភារកិច្ចដូចខាងក្រោម៖

- ទទួលសំណាក ឬគំរូផលិតផល ផ្តល់វិញ្ញាបនបត្រ និងសម្របសម្រួលការងារជាមួយអតិថិជន
- សិក្សាស្រាវជ្រាវ កំណត់គោលដៅ ស្វែងរក ពង្រីង និងពង្រីកទីផ្សាររបស់ **ម.ជ.វ.ប.ន.**និងរៀបចំយុទ្ធសាស្ត្រតម្លៃប្រកួតប្រជែងសមស្រប
- រៀបចំយុទ្ធសាស្ត្រទីផ្សារ ផ្សព្វផ្សាយសេវាកម្មស្តីពីការធ្វើតេស្តវិភាគលើផលិតផលឱ្យបានទូលាយ ដោយផ្សារភ្ជាប់ទៅនឹងឧត្តមភាពរបស់ **ម.ជ.វ.ប.ន.**
- សម្របសម្រួលជាមួយមន្ទីរពិសោធន៍ក្នុង **ម.ជ.វ.ប.ន.**ដើម្បីផ្តល់ការប្រឹក្សាយោបល់ជូនអតិថិជនពីលទ្ធផលនៃការធ្វើតេស្តវិភាគ ដើម្បីលើកកម្ពស់គុណភាពនិងសុវត្ថិភាពផលិតផល
- សិក្សាស្រាវជ្រាវវិធីសាស្ត្រធ្វើតេស្តវិភាគថ្មីៗ ដែលជាតម្រូវការទីផ្សារដើម្បីផ្តល់សេវាតេស្តវិភាគរបស់ **ម.ជ.វ.ប.ន.** ដែលអាចឆ្លើយតបការងារផ្នែកឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- ផ្តល់ការសិក្សាស្រាវជ្រាវ និងការប្រឹក្សាដល់ឧស្សាហកម្ម សិប្បកម្ម សហគ្រាសធុនតូច និងមធ្យមលើការវិភាគគុណភាពផលិតផល ការសិក្សាអាយុកាលផលិតផល និងការធ្វើឱ្យប្រសើរឡើងនៃគុណភាពផលិតផល
- សម្របសម្រួល និងចូលរួមក្នុងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការជាមួយមន្ទីរពិសោធន៍ វិទ្យាស្ថានស្រាវជ្រាវ ស្ថាប័នជាតិ អន្តរជាតិ ឯកជន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីការស្រាវជ្រាវអភិវឌ្ឍន៍គុណភាពផលិតផល
- សម្របសម្រួលក្នុងសំណើធ្វើតេស្តលើគំរូផលិតផលដែល **ម.ជ.ទ.ប.ន.** ចុះយក ឬសហការចុះយក តាមភាពចាំបាច់
- កៀរគរធនធានជាតិនិងអន្តរជាតិ ដើម្បីគាំទ្រដល់បេសកកម្មរបស់ **ម.ជ.ទ.ប.ន.**
- បូកសរុបរបាយការណ៍ជូននាយក **ម.ជ.ទ.ប.ន.**
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយក **ម.ជ.ទ.ប.ន.**។

**ប្រការ៧.-**

មន្ទីរពិសោធន៍មីក្រូជីវសាស្ត្រ មានភារកិច្ចដូចខាងក្រោម៖

- ធ្វើតេស្តវិភាគផ្នែកមីក្រូជីវសាស្ត្រលើម្ហូបអាហារ ទឹក សំណល់រឹងរាវ គុណភាពខ្យល់
- ធ្វើតេស្ត វិភាគវត្ថុធាតុដើម និងផលិតផលឧស្សាហកម្ម សិប្បកម្មលើផ្នែកវិទ្យាសាស្ត្រគុណជាត
- វិភាគអត្តសញ្ញាណនៃអតិសុខុមប្រាណដោយប្រើបច្ចេកវិទ្យាទំនើប
- ចូលរួមប្រឹក្សាយោបល់លើលទ្ធផលការធ្វើតេស្តវិភាគ សម្រាប់កែលម្អ គុណភាព សុវត្ថិភាព និងប្រព័ន្ធគ្រប់គ្រងគុណភាពមន្ទីរពិសោធន៍ផ្នែកមីក្រូជីវសាស្ត្រ
- ចូលរួមផ្តល់ប្រឹក្សាដល់អតិថិជនស្តីពីការកែលម្អនិងលើកកម្ពស់គុណភាព សុវត្ថិភាពម្ហូបអាហារ និងទឹក
- ចូលរួមសិក្សាស្រាវជ្រាវនិងអភិវឌ្ឍវិធីសាស្ត្រនៃការធ្វើតេស្តវិភាគផ្នែកមីក្រូជីវសាស្ត្រ
- បូកសរុបរបាយការណ៍ជូននាយក **ម.ជ.ទ.ប.ន.**
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយក **ម.ជ.ទ.ប.ន.**។

**ប្រការ៨.-**

មន្ទីរពិសោធន៍គីមីសាស្ត្រទឹក មានភារកិច្ចដូចខាងក្រោម៖

- ធ្វើតេស្តវិភាគគុណភាពទឹកគ្រប់ប្រភេទលើផ្នែកគីមីសាស្ត្រនិងលោហធាតុ
- កែលម្អនិងអនុវត្តជំនាញបច្ចេកទេសក្នុងការធ្វើតេស្តវិភាគផ្នែកគីមីសាស្ត្រនិងលោហធាតុ
- ចូលរួមប្រឹក្សាយោបល់លើលទ្ធផលការធ្វើតេស្តវិភាគសម្រាប់កែលម្អ គុណភាព សុវត្ថិភាព និងប្រព័ន្ធគ្រប់គ្រងគុណភាពមន្ទីរពិសោធន៍ផ្នែកគីមីសាស្ត្រទឹក
- ចូលរួមផ្តល់ប្រឹក្សាដល់អតិថិជនស្តីពីការកែលម្អ និងលើកកម្ពស់គុណភាពសុវត្ថិភាព ក្នុងការប្រើប្រាស់និងផលិតទឹកគ្រប់ប្រភេទ
- ចូលរួមសិក្សាស្រាវជ្រាវនិងអភិវឌ្ឍវិធីសាស្ត្រនៃការធ្វើតេស្តវិភាគផ្នែកគីមីសាស្ត្រទឹក
- បូកសរុបរបាយការណ៍ជូននាយក **ម.ជ.ទ.ប.ន.**
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយក **ម.ជ.ទ.ប.ន.**។

**ប្រការ៩.-**

មន្ទីរពិសោធន៍គីមីសាស្ត្រម្ហូបអាហារ មានភារកិច្ចដូចខាងក្រោម៖

- ធ្វើតេស្តវិភាគម្ហូបអាហារនិងភេសជ្ជៈលើញ្ញាណជាតុ (sensory properties) លក្ខណៈគីមី គុណតម្លៃនៃអាហារូបត្ថម្ភ (nutritional value) និង លក្ខណរូប (physical properties) ជាផ្នែកសំខាន់មួយនៃការធានាគុណភាពការអនុលោមតាមច្បាប់និងការអភិវឌ្ឍផលិតផល
- ធ្វើតេស្តវិភាគផ្នែកគីមីសាស្ត្រលើសារធាតុច្រេះ ឬស្នឹមនៃសំបកវេចខ្ចប់ ធុងស្តុកជាលោហៈដែលសម្រាប់ដាក់ម្ហូបអាហារនិងភេសជ្ជៈ និងគ្រឿងប្រដាប់ប្រើប្រាស់ជាមួយម្ហូបអាហារ
- ចូលរួមប្រឹក្សាយោបល់លើលទ្ធផលការធ្វើតេស្តវិភាគ សម្រាប់កែលម្អ គុណភាព សុវត្ថិភាព និងប្រព័ន្ធគ្រប់គ្រងគុណភាពមន្ទីរពិសោធន៍ផ្នែកគីមីសាស្ត្រម្ហូបអាហារ
- ចូលរួមផ្តល់ប្រឹក្សាដល់អតិថិជនស្តីពីការកែលម្អ និងលើកកម្ពស់គុណភាព សុវត្ថិភាពក្នុងការប្រើប្រាស់និងផលិតម្ហូបអាហារ និងភេសជ្ជៈ
- ចូលរួមសិក្សាស្រាវជ្រាវនិងអភិវឌ្ឍវិធីសាស្ត្រនៃការធ្វើតេស្តវិភាគផ្នែកគីមីសាស្ត្រម្ហូបអាហារនិងភេសជ្ជៈ
- សហការបង្កើតបច្ចេកវិជ្ជាគាំទ្រដល់ការផលិតអាហារមានសុវត្ថិភាព
- បូកសរុបរបាយការណ៍ជូននាយក **ម.ជ.ទ.ប.ន.**
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយក **ម.ជ.ទ.ប.ន.**។

**ប្រការ១០.-**

មន្ទីរពិសោធន៍គីមីសាស្ត្រមិនមែនម្ហូបអាហារ មានភារកិច្ចដូចខាងក្រោម៖

- ធ្វើតេស្តវិភាគផ្នែកគីមីសាស្ត្រលើផលិតផលគីមីឧស្សាហកម្ម សារធាតុលាងសម្អាត សាប៊ូ ប្រដាប់ប្រដាក្មេងលេង ថ្នាំពុលកសិកម្ម លោហៈនិងអលោហៈ ឥដ្ឋនិងក្បឿង សំឡីកែវ ស៊ីម៉ង់ត៍ ប្លាស្ទិក ថ្នាំលាប រែកនីប្រេងឥន្ធនៈ ជី ដីកសិកម្ម វត្ថុធាតុសំណង់។ល។
- ធ្វើតេស្តវិភាគផ្នែកគីមីសាស្ត្រលើផលិតផលវាយនភណ្ឌ ស្បែក ក្រដាស ស្បែកជើង សម្ភារវេចខ្ចប់ សារធាតុគីមី វត្ថុធាតុដើមសម្រាប់ដំណើរការផលិតកម្ម ផលិតផលគីមីមិនមែនម្ហូបអាហារ គុណភាពខ្យល់ និងផលិតផលគីមីមិនមែនម្ហូបអាហារផ្សេងទៀត
- ចូលរួមប្រឹក្សាយោបល់លើលទ្ធផលការធ្វើតេស្តវិភាគ សម្រាប់កែលម្អ គុណភាព សុវត្ថិភាព និងប្រព័ន្ធគ្រប់គ្រងគុណភាពមន្ទីរពិសោធន៍ផ្នែកគីមីសាស្ត្រមិនមែនម្ហូបអាហារ
- ចូលរួមផ្តល់ប្រឹក្សាដល់អតិថិជនស្តីពីការកែលម្អ និងលើកកម្ពស់គុណភាព សុវត្ថិភាពក្នុងការប្រើប្រាស់និងផលិតគីមីឧស្សាហកម្មផ្សេងៗចូលរួមសិក្សាស្រាវជ្រាវ និងអភិវឌ្ឍវិធីសាស្ត្រនៃការធ្វើតេស្តវិភាគផ្នែកគីមីសាស្ត្រមិនមែនម្ហូបអាហារ
- បូកសរុបរបាយការណ៍ជូននាយក **ម.ជ.ទ.ប.ន.**
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយក **ម.ជ.ទ.ប.ន.**។

**ប្រការ១១.-**

មន្ទីរពិសោធន៍មេកានិក អគ្គិសនី និងអេឡិចត្រូនិក មានភារកិច្ចដូចខាងក្រោម៖

- ធ្វើតេស្តផ្នែកមេកានិកនិងសុវត្ថិភាពនៃផលិតផលគ្រឿងទ្រទ្រង់ទម្ងន់និងផលិតផលផ្សេងទៀត
- ធ្វើតេស្តផ្នែកអគ្គិសនីនិងសុវត្ថិភាពនៃផលិតផលអគ្គិសនី មានដូចជាខ្សែចម្លង ឧបករណ៍បំភ្លឺ និងបំប្លែង ។ល។
- ធ្វើតេស្តផ្នែកអេឡិចត្រូនិក និងសុវត្ថិភាពនៃផលិតផលអេឡិចត្រូនិកមានដូចជាញាណ្ណូបករណ៍
- ចូលរួមផ្តល់ប្រឹក្សាដល់អតិថិជនស្តីពីការកែលម្អគុណភាព សុវត្ថិភាពផលិតផល ការធ្វើតេស្ត និងប្រព័ន្ធគ្រប់គ្រងគុណភាពមន្ទីរពិសោធន៍ផ្នែកមេកានិក ផលិតផលអគ្គិសនីនិងអេឡិចត្រូនិក។ល។

- ចូលរួមសិក្សាស្រាវជ្រាវនិងអភិវឌ្ឍវិធីសាស្ត្រនៃការធ្វើតេស្តផ្នែកមេកានិក និងសុវត្ថិភាពផលិតផល អគ្គិសនី និងអេឡិចត្រូនិក
- បូកសរុបរបាយការណ៍ជូននាយក **ម.ជ.វ.ប.ន.**
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីនាយក **ម.ជ.វ.ប.ន.**។

## ជំពូកទី៣
## អវសានបញ្ញត្តិ

**ប្រការ១២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ២ កើត ខែ ផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**ហែម វណ្ណឌី**

**កន្លែងទទួល ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ១៣
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងលេខ:០៤០ ៣៦០ ន..................ចុះថ្ងៃទី ១៤......ខែ...កុម្ភៈ...ឆ្នាំ២០២៦
ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (**ម.ជ.វ.ប.ន.**)

**អង្គការលេខរបស់មន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**



សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណាសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី